**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ: ០៣៤ សរ ណន

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៣

# សេចក្តីណែនាំ
## ស្តីពីការរៀបចំបង្កើតគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម
## របស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

យោងតាមប្រកាសអន្តរក្រសួងលេខ៣២៤ សហវ.ប្រក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៣ របស់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីនីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្រសួងមហាផ្ទៃសូមធ្វើការណែនាំអំពីការរៀបចំបង្កើតគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដូចខាងក្រោម ៖

**១. ការរៀបចំបង្កើតគណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

**ក. ការរៀបចំបង្កើតគណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត**

គណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត មានសមាសភាពដូចបានកំណត់នៅក្នុងប្រការ៦នៃប្រកាសអន្តរក្រសួងលេខ៣២៤ សហវ.ប្រក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៣។

អភិបាលនៃគណៈអភិបាលរាជធានី ខេត្តដោយមានការឯកភាពក្នុងគណៈអភិបាលរបស់ខ្លួន ត្រូវសម្រេចជ្រើសរើសអភិបាលរង០១រូប ជាបេក្ខជនអនុប្រធានគណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្តរបស់ខ្លួន។

ក្រុមប្រឹក្សារាជធានី ខេត្តត្រូវរៀបចំកិច្ចប្រជុំរបស់ខ្លួន ដើម្បីសម្រេចជ្រើសរើសសមាជិកក្រុមប្រឹក្សារាជធានី ខេត្តយ៉ាងច្រើន០៣រូប ដែលក្នុងនោះត្រូវមានស្ត្រីជាបេក្ខជនសមាជិកនៃគណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត។ ប្រធានក្រុមប្រឹក្សារាជធានី ខេត្តត្រូវបញ្ជូនឈ្មោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្តដែលបានជ្រើសរើសទាំងនោះជាលាយល័ក្ខណ៍អក្សរទៅអភិបាលនៃគណៈអភិបាលរាជធានី ខេត្តដើម្បីបញ្ចូលទៅក្នុងសំណើសមាសភាពគណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត។

នៅពេលទទួលបានបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សា ជាបេក្ខជនសមាជិកគណៈកម្មាធិការលទ្ធកម្ម និងកំណត់បានពីសមាសភាពអភិបាលរង០១រូបជាបេក្ខជនអនុប្រធានគណៈកម្មាធិការលទ្ធកម្ម អភិបាលនៃគណៈអភិបាលរាជធានី ខេត្តត្រូវរៀបចំសេចក្តីព្រាងសេចក្តីសម្រេចស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ដោយរួមបញ្ចូលនូវសមាសភាពដទៃទៀតដូចបានកំណត់នៅក្នុងប្រការ៦នៃប្រកាសអន្តរក្រសួងលេខ៣២៤ សហវ.ប្រក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៣ ដើម្បីដាក់ជូនក្រុមប្រឹក្សារាជធានី ខេត្តពិនិត្យ និងអនុម័ត។

ទីស្តីការក្រសួងមហាផ្ទៃ លេខ ២៧៥ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣
ទូរសារ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣ e-mail: moi@interior.gov.kh web: www.interior.gov.kh

ក្រុមប្រឹក្សារាជធានី ខេត្តត្រូវរៀបចំកិច្ចប្រជុំដើម្បីពិនិត្យ និងអនុម័តលើសេចក្តីព្រាងសេចក្តីសម្រេចខាងលើនេះទៅតាមបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។

ផ្អែកតាមការសម្រេចរបស់ក្រុមប្រឹក្សា អភិបាលនៃគណៈអភិបាលរាជធានី ខេត្តត្រូវរៀបចំសេចក្តីព្រាងសេចក្តីសម្រេចចុងក្រោយស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្មនេះ ដើម្បីដាក់ជូនប្រធានក្រុមប្រឹក្សារាជធានី ខេត្តចុះហត្ថលេខា។

**ខ. ការរៀបចំបង្កើតគណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ**

គណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ មានសមាសភាពដូចបានកំណត់នៅក្នុងប្រការ៧នៃប្រកាសអន្តរក្រសួងលេខ៣២៤ សហវ.ប្រក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៣។

អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ដោយមានការឯកភាពក្នុងគណៈអភិបាលរបស់ខ្លួនត្រូវសម្រេចជ្រើសរើសអភិបាលរង០១រូប ជាបេក្ខជនអនុប្រធានគណៈកម្មាធិការលទ្ធកម្មនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌរបស់ខ្លួន។

ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌត្រូវរៀបចំកិច្ចប្រជុំរបស់ខ្លួន ដើម្បីសម្រេចជ្រើសរើសសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌយ៉ាងច្រើន០៣រូប ដែលក្នុងនោះត្រូវមានស្ត្រីជាបេក្ខជនសមាជិកនៃគណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។ ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌត្រូវបញ្ជូនឈ្មោះសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌដែលបានជ្រើសរើសទាំងនោះជាលាយល័ក្ខណ៍អក្សរទៅអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌដើម្បីបញ្ចូលទៅក្នុងសំណើសមាសភាពគណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។

នៅពេលទទួលបានបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សា ជាបេក្ខជនសមាជិកគណៈកម្មាធិការលទ្ធកម្ម និងកំណត់បានពីសមាសភាពអភិបាលរង០១រូបជាបេក្ខជនអនុប្រធានគណៈកម្មាធិការលទ្ធកម្ម អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌត្រូវរៀបចំសេចក្តីព្រាងសេចក្តីសម្រេចស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដោយរួមបញ្ចូលនូវសមាសភាពដទៃទៀតដូចបានកំណត់នៅក្នុងប្រការ៧នៃប្រកាសអន្តរក្រសួងលេខ៣២៤ សហវ.ប្រក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៣ ដើម្បីដាក់ជូនក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌពិនិត្យ និងអនុម័ត។

ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌត្រូវរៀបចំកិច្ចប្រជុំដើម្បីពិនិត្យ និងអនុម័តលើសេចក្តីព្រាងសេចក្តីសម្រេចខាងលើនេះទៅតាមបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។

ផ្អែកតាមការសម្រេចរបស់ក្រុមប្រឹក្សា អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌត្រូវរៀបចំសេចក្តីព្រាងសេចក្តីសម្រេចចុងក្រោយស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្មនេះ ដើម្បីដាក់ជូនប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌចុះហត្ថលេខា។

**២. ការរៀបចំបង្កើតអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

ផ្អែកតាមខ្លឹមសារនៃប្រការ៤ ប្រការ១៣ និងប្រការ១៧នៃប្រកាសអន្តរក្រសួងលេខ ៣២៤ សហវ.ប្រក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៣ អង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវបានបង្កើតឡើងនៅក្នុងរចនាសម្ព័ន្ធសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ អាស្រ័យហេតុនេះ រដ្ឋបាល

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌពុំចាំបាច់លើកសំណើ ឬចេញសេចក្ដីសម្រេច ឬដីការបស់ក្រុមប្រឹក្សាដើម្បីបង្កើតអង្គភាពលទ្ធកម្មរបស់រដ្ឋបាលខ្លួនទៀតឡើយ។

អង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវដឹកនាំដោយប្រធាន០១រូប និងមានអនុប្រធានយ៉ាងច្រើន០២រូបជាជំនួយការ។

ដើម្បីរៀបចំតែងតាំងនូវមន្ត្រីសម្រាប់មុខតំណែងខាងលើនេះ រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវអនុវត្តតាមគោលការណ៍ និងនីតិវិធីដូចខាងក្រោម ៖

**ក. ការតែងតាំងមន្ត្រីសម្រាប់មុខតំណែងប្រធាន និងអនុប្រធានអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត**

អភិបាលនៃគណៈអភិបាលរាជធានី ខេត្តត្រូវធ្វើការពិគ្រោះយោបល់ឲ្យមានការឯកភាពគ្នាក្នុងគណៈអភិបាលរបស់ខ្លួន ដើម្បីកំណត់ជ្រើសរើសបេក្ខជនសម្រាប់ស្នើតែងតាំងក្នុងមុខតំណែងប្រធាន ឬ/និងអនុប្រធានអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្តដោយផ្អែកលើលក្ខណសម្បត្តិ សមត្ថភាព និងបទពិសោធន៍ការងារ។

**ក.១. ក្នុងករណីបេក្ខជនប្រធាន ឬ/និងអនុប្រធានអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត គឺជាប្រធាន ឬ/និងអនុប្រធានការិយាល័យលទ្ធកម្មនៃទីចាត់ការហិរញ្ញវត្ថុសាលារាជធានី ខេត្តបច្ចុប្បន្ន**

- អភិបាលនៃគណៈអភិបាលរាជធានី ខេត្តត្រូវលើកសំណើបេក្ខជនប្រធាន ឬ/និងអនុប្រធានអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្តដើម្បីដាក់ជូនក្រុមប្រឹក្សារាជធានី ខេត្តពិនិត្យ និងអនុម័ត។
- បន្ទាប់ពីទទួលបានសំណើបេក្ខជនប្រធាន ឬ/និងអនុប្រធានអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុមប្រឹក្សារាជធានី ខេត្តត្រូវរៀបចំកិច្ចប្រជុំដើម្បីពិនិត្យ និងអនុម័តទៅតាមបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។
- ក្រោយពេលទទួលបានការអនុម័តពីក្រុមប្រឹក្សារាជធានី ខេត្ត អភិបាលនៃគណៈអភិបាលរាជធានី ខេត្តត្រូវលើកសំណើសុំតែងតាំងប្រធាន ឬ/និងអនុប្រធានអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្តដោយភ្ជាប់មកជាមួយនូវកំណត់ហេតុនៃកិច្ចប្រជុំគណៈអភិបាល និងកិច្ចប្រជុំក្រុមប្រឹក្សាជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដើម្បីពិនិត្យ និងសម្រេចទៅតាមគោលការណ៍ បែបបទ និងនីតិវិធីកំណត់។

**ក.២. ក្នុងករណីបេក្ខជនប្រធាន ឬ/និងអនុប្រធានអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត មិនមែនជាប្រធាន និងអនុប្រធានការិយាល័យលទ្ធកម្មនៃទីចាត់ការហិរញ្ញវត្ថុសាលារាជធានី ខេត្តបច្ចុប្បន្ន**

- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដោយមានការឯកភាពក្នុងគណៈអភិបាលត្រូវលើកសំណើបេក្ខជនប្រធាន ឬ/និងអនុប្រធានអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្តដើម្បីដាក់ជូនក្រុមប្រឹក្សារាជធានី ខេត្តពិនិត្យ និងអនុម័ត។ សំណើនេះត្រូវបញ្ជាក់ឲ្យបានច្បាស់លាស់

អំពីមូលហេតុដែលមិនស្នើតែងតាំងប្រធាន ឬ/និងអនុប្រធានការិយាល័យលទ្ធកម្មនៃទីចាត់ការហិរញ្ញវត្ថុសាលារាជធានី ខេត្តបច្ចុប្បន្នធ្វើជាបេក្ខជនប្រធាន ឬ/និងអនុប្រធានអង្គភាពលទ្ធកម្ម។

- ចំពោះបេក្ខជន ដែលស្នើតែងតាំងសម្រាប់មុខតំណែងប្រធានអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ត្រូវជ្រើសចេញពីមន្ត្រីរាជការស៊ីវិលក្របខ័ណ្ឌក្រសួងមហាផ្ទៃដែលបំពេញការងារនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ផ្អែកតាមលក្ខណសម្បត្តិដូចមានចែងក្នុងប្រការ១៥នៃប្រកាសអន្តរក្រសួងលេខ៣២៤ សហវ.ប្រក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៣។
- ក្នុងករណីដែលពុំអាចជ្រើសរើសបាននូវបេក្ខជនតាមការកំណត់ខាងលើ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដោយមានការឯកភាពពីគណៈអភិបាល និងក្រុមប្រឹក្សារបស់ខ្លួន ត្រូវស្នើសុំយោបល់ពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីស្នើសុំផ្ទេរមន្ត្រីមកពីក្រសួងមហាផ្ទៃ ឬពីសាលារាជធានី ខេត្តផ្សេង ឬពីក្របខ័ណ្ឌក្រសួង ស្ថាប័នផ្សេងទៀតតាមនីតិវិធីជាធរមាន។

- បន្ទាប់ពីទទួលបានសំណើបេក្ខជនប្រធាន ឬ/និងអនុប្រធានអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុមប្រឹក្សារាជធានី ខេត្តត្រូវរៀបចំកិច្ចប្រជុំដើម្បីពិនិត្យ និងអនុម័តទៅតាមបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។
- ក្រោយពេលទទួលបានការអនុម័តពីក្រុមប្រឹក្សា អភិបាលនៃគណៈអភិបាលជានី ខេត្តត្រូវលើកសំណើសុំតែងតាំងប្រធាន ឬ/និងអនុប្រធានអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្តដោយភ្ជាប់មកជាមួយនូវកំណត់ហេតុនៃកិច្ចប្រជុំគណៈអភិបាល និងកិច្ចប្រជុំក្រុមប្រឹក្សាជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដើម្បីពិនិត្យ និងសម្រេចទៅតាមគោលការណ៍ បែបបទ និងនីតិវិធីកំណត់។
- បន្ទាប់ពីការតែងតាំងប្រធាន ឬ/និងអនុប្រធានអង្គភាពលទ្ធកម្មរបស់ខ្លួន រដ្ឋបាលរាជធានី ខេត្ត ត្រូវផ្ទេរមន្ត្រី បុគ្គលិក ឧបករណ៍ សម្ភារៈ មធ្យោបាយ និងការងារពាក់ព័ន្ធនឹងកិច្ចការលទ្ធកម្មពីការិយាល័យលទ្ធកម្មនៃទីចាត់ការហិរញ្ញវត្ថុរបស់សាលារាជធានី ខេត្តទៅឲ្យអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត។

## ខ. ការតែងតាំងមន្ត្រីសម្រាប់មុខតំណែងប្រធាន ឬ/និងអនុប្រធានអង្គភាពលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ

ការតែងតាំងមន្ត្រីសម្រាប់មុខតំណែងប្រធាន ឬ/និងអនុប្រធានអង្គភាពលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តដូចខាងក្រោម ៖

- អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ដោយមានការឯកភាពក្នុងគណៈអភិបាល ត្រូវលើកសំណើបេក្ខជនប្រធាន ឬ/និងអនុប្រធានអង្គភាពលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីដាក់ជូនក្រុមប្រឹក្សារបស់ខ្លួនពិនិត្យ និងអនុម័ត។
  - បេក្ខជនដែលស្នើតែងតាំងសម្រាប់មុខតំណែងប្រធានអង្គភាពលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវជ្រើសចេញពីមន្ត្រីរាជការស៊ីវិលក្របខ័ណ្ឌក្រសួងមហាផ្ទៃដែលបំពេញការងារនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ដោយផ្អែកតាមលក្ខណសម្បត្តិ

ដូចមានចែងក្នុងប្រការ១៥នៃប្រកាសអន្តរក្រសួងលេខ៣២៤ សហវ.ប្រក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៣។

- ក្នុងករណីដែលពុំអាចជ្រើសរើសបាននូវបេក្ខជនដូចបានកំណត់ខាងលើ អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌដោយមានការឯកភាពពីគណៈអភិបាល និងក្រុមប្រឹក្សារបស់ខ្លួន អាចស្នើសុំយោបល់ពីអភិបាលនៃគណៈអភិបាលរាជធានី ខេត្តដើម្បីសម្របសម្រួលជ្រើសរើសបេក្ខជនដែលមានលក្ខណសម្បត្តិ ដូចប្រការ១៥នៃប្រកាសអន្តរក្រសួងលេខ ៣២៤ សហវ.ប្រក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៣ ពីសាលារាជធានី ខេត្ត ឬពីសាលាក្រុង ស្រុក ខណ្ឌផ្សេងទៀត ឬស្នើសុំផ្ទេរមន្ត្រីពីក្របខ័ណ្ឌក្រសួង ស្ថាប័នផ្សេងទៀតតាមនីតិវិធីជាធរមាន។
- ក្នុងករណីនៅតែពុំអាចជ្រើសរើសបាននូវបេក្ខជនជាប្រធានអង្គភាពលទ្ធកម្មតាមការកំណត់ក្នុងចំណុចទាំងពីរខាងលើ អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌដោយមានការឯកភាពពីគណៈអភិបាល និងក្រុមប្រឹក្សារបស់ខ្លួន ត្រូវជ្រើសរើសបេក្ខជនដែលមានលក្ខណសម្បត្តិសមស្របដើម្បីស្នើសុំតែងតាំងជាអនុប្រធានអង្គភាពលទ្ធកម្មយ៉ាងច្រើន០២រូប។

- នៅពេលទទួលបានសំណើបេក្ខជនប្រធាន ឬ/និងអនុប្រធានអង្គភាពលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សាត្រូវរៀបចំកិច្ចប្រជុំ ដើម្បីពិនិត្យ និងអនុម័តតាមបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។
- ក្រោយពេលទទួលបានការអនុម័តពីក្រុមប្រឹក្សា អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវលើកសំណើតែងតាំងប្រធាន ឬ/និងអនុប្រធានអង្គភាពលទ្ធកម្មរបស់រដ្ឋបាល ក្រុង ស្រុក ខណ្ឌ ជូនអភិបាលនៃគណៈអភិបាលរាជធានី ខេត្តដើម្បីធ្វើសំណើជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីពិនិត្យ និងសម្រេចទៅតាមគោលការណ៍ បែបបទ និងនីតិវិធីកំណត់។
- បន្ទាប់ពីការតែងតាំងប្រធាន ឬ/និងអនុប្រធានអង្គភាពលទ្ធកម្មរបស់ខ្លួន រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវផ្ទេរមន្ត្រី បុគ្គលិក ឧបករណ៍ សម្ភារៈ មធ្យោបាយ និងការងារពាក់ព័ន្ធនឹងកិច្ចការលទ្ធកម្មពីការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុក្រុង ស្រុក ខណ្ឌឲ្យទៅអង្គភាពលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។
- ក្នុងករណីពុំអាចតែងតាំងប្រធានអង្គភាពលទ្ធកម្មបាន អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌដោយមានការឯកភាពពីគណៈអភិបាល និងក្រុមប្រឹក្សារបស់ខ្លួន ត្រូវជ្រើសរើសអនុប្រធានអង្គភាពលទ្ធកម្ម០១រូប ឲ្យទទួលបន្ទុករួម និងជាលេខាធិការនៃគណៈកម្មាធិការលទ្ធកម្ម។

## ៣. កិច្ចប្រជុំរបស់ក្រុមប្រឹក្សាពាក់ព័ន្ធនឹងការស្នើបេក្ខជនសម្រាប់មុខតំណែងប្រធាន ឬ/និងអនុប្រធានអង្គភាពលទ្ធកម្មរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

រាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សា ដើម្បីពិភាក្សា និងអនុម័តលើសំណើបេក្ខជនសម្រាប់មុខតំណែងប្រធាន ឬ/និងអនុប្រធានអង្គភាពលទ្ធកម្មរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើឡើងជាសម្ងាត់។ ក្រុមប្រឹក្សាត្រូវធ្វើការអនុម័តតាមរយៈការបោះឆ្នោតជាសម្ងាត់។ រាល់កំណត់ហេតុកិច្ចប្រជុំនានាពាក់ព័ន្ធនឹងកិច្ច

ប្រជុំជាសម្ងាត់នេះ មិនត្រូវផ្សព្វផ្សាយជាសាធារណៈឡើយ។ ក្រុមប្រឹក្សាអាចអនុញ្ញាតឲ្យដកស្រង់ខ្លឹមសារគោលនៃកិច្ចប្រជុំសម្រាប់ផ្សព្វផ្សាយជាសាធារណៈ ប៉ុន្តែមិនត្រូវធ្វើឲ្យប៉ះពាល់ដល់ព័ត៌មានផ្ទាល់ខ្លួន កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់បុគ្គលឡើយ។

ទទួលបានសេចក្តីណែនាំនេះ រដ្ឋបាលរាជធានី រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក និងរដ្ឋបាលខណ្ឌត្រូវចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាព។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

ស ខេង

**<u>កន្លែងទទួល</u>**

- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួង ស្ថាប័នសមាជិក គ.ជ.អ.ប.*
- *ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល*
- *លេខាធិការដ្ឋាន គ.ជ.អ.ប*
- *ឯកសារ កាលប្បវត្តិ*